00337370

E65/3

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 04 / JUN / 2009
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Tuy

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| កាលបរិច្ឆេទ | : | ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ |
| ភាគីដាក់ជូនសារណា | : | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) |
| ភាសាដើម | : | ភាសាអង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ | : | សាធារណៈ |

---

# ក្រុម២ - សារណាតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបទៅនឹង សំណើដាក់ដោយ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១ ស្តីពីការបង្ហើបឲ្យដឹងដល់ភាគីនូវរបាយការណ៍របស់ UN-OIOS

---

**<u>ដាក់ជូនដោយ</u>:**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

**<u>ជូនចំពោះ</u>:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម **យ៉ា សុខន**

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម **ធូ មណី**

**<u>ចម្លងជូន</u>:**

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ:**

លោក កាំង ហ្គេក អ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ

លោក François ROUX

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**មេធាវីតំណាងដើមបណ្ដឹង**

**រដ្ឋប្បវេណី:**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោក Pirre-Olivier SUR

កញ្ញា ទី ស្រ៊ីនណា

លោកស្រី Brianne McGONIGLE

លោក Alain WERNER

លោក Karim KHAN

លោកស្រី Annie DELAHAIE

លោកស្រី Elizabeth RABESANDRATANA

# I. សេចក្ដីផ្ដើម

១. កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីដើមបណ្ដឹងក្រុម១ បានដាក់សំណើទៅដល់អង្គជំនុំជម្រះដើម្បីស្នើសុំឱ្យបង្ហាញនូវរបាយការណ៍ថតចម្លង របស់ការិយាល័យត្រួតពិនិត្យសេវាកម្មផ្ទៃក្នុង(ការិយាល័យត្រួតពិនិត្យ-OIOS)របស់សហប្រជាជាតិ ដែលបានរាយការណ៍ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ជូនដល់ភាគីទាំងអស់ដែលកំពុងបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ("សំណើសុំ")។[1] របាយការណ៍នេះមានលទ្ធផលនៃការស៊ើបអង្កេតផ្ទៃក្នុងដែលធ្វើឡើងការិយាល័យត្រួតពិនិត្យ បន្ទាប់ពីមានការចោទប្រកាន់អំពីការសូកប៉ាន់ដល់មន្ត្រីជាន់ខ្ពស់ដើម្បីទទួលបានការងារធ្វើនៅក្នុងអ.វ.ត.ក។ សហមេធាវីបានអះអាងថា ការបង្ហាញឱ្យដឹងអំពីរបាយការណ៍នេះ គឺជាមធ្យោបាយមួយដើម្បីស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ[2] ក៏ដូចជាដើម្បីធានាដល់កិច្ចដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ។[3]

២. នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់ភាគីទាំងអស់ឱ្យដាក់សេចក្ដីសន្និដ្ឋានជាលាយល័ក្ខអក្សរពាក់ព័ន្ធទៅនឹងសំណើនេះ។[4] អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់ភាគីឱ្យបញ្ជាក់ប្រាប់ថាតើការបង្ហាញពីរបាយការណ៍នេះដល់ភាគី មានផលប៉ះពាល់ដល់ភាពត្រឹមត្រូវនៃដំណើរការសវនាការក្នុងសំណុំរឿងបច្ចុប្បន្ននេះយ៉ាងដូចម្ដេច។

៣. សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី២ បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ស្របទៅតាមសំណើ ពីព្រោះការបង្ហើបឱ្យដឹងអំពីរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យនេះ គឺមានសារៈសំខាន់ដើម្បីស្វែងរកការពិត ពាក់ព័ន្ធទៅនឹងការសូកប៉ាន់ដល់មន្ត្រីជាន់ខ្ពស់ដើម្បី

---

[1] *រឿងក្ដី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ក្រុម១- សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS* ("សំណើ"), ឯកសារលេខ E65, ERN.

[2] ដូចជើងទំព័រខាងលើ, កថាខណ្ឌ១៧។

[3] ដូចជើងទំព័រខាងលើ, កថាខណ្ឌ១៣។

[4] *រឿងក្ដី កាំង ហ្គេកអ៊ាវ,* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, *សេចក្ដីណែនាំអំពីការកំណត់ពេលវេលាសម្រាប់សារណាតបរបស់ភាគីទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូងជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS* ។

ទទួលបានការងារធ្វើនៅក្នុងអ.វ.ត.ក ក៏ដូចជាដើម្បីធានាដល់កិច្ចដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ។ លើសពីនេះទៅទៀត ដើម្បីធ្វើឱ្យមានតម្លាភាព អង្គជំនុំជម្រះសាលាដំបូងត្រូវឆ្លើយតបទៅនឹងគោលដៅដែលតម្រូវឱ្យបំពេញយោងតាមវិធាន២១ នៃវិធានផ្ទៃក្នុង។

## II. ឧត្តិករណ៍

៤. ការចោទប្រកាន់អំពីការសូកប៉ាន់ដែលបានកើតមានឡើងនៅក្នុងអ.វ.ត.ក គឺជាបញ្ហាមួយដែលបានលើកឡើងអស់រយៈពេលប្រហែលពីរឆ្នាំមកហើយ។[5] ការបរាជ័យដែលចេះតែបន្តក្នុងការដោះស្រាយបញ្ហាចោទប្រកាន់នេះ បាននាំឱ្យមានការជាប់គាំងមួយ។ ដូចដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍រួម ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងបញ្ហាចោទប្រកាន់អំពីអំពើពុករលួយ[6] ស្ថានភាពបែបនេះ គឺពាក់ព័ន្ធជាបឋមទៅដល់ផលប្រយោជន៍ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ ដូចគ្នាទៅនឹងប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយផ្ទាល់ដោយអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងកំឡុងពេលរបបខ្មែរក្រហម ជនរងគ្រោះដើមបណ្តឹងរដ្ឋវេណី បានរង់ចាំអស់រយៈពេលជាយូរដើម្បីស្វែងរកយុត្តិធម៌ពិតប្រាកដ។ សេចក្តីសង្ឃឹមទាំងនេះ អាចសម្រេចបាន លុះត្រាតែមានកិច្ចដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ ដែលគាំទ្រដោយគោលការណ៍ឯករាជ្យភាព និងអនាគតិ។ ដូច្នេះដូចទៅនឹងអ្វីដែលបង្ហាញនូវឃ្លាខាងក្រោម ការបញ្ចើបឱ្យដឹងពីរបាយការណ៍នេះ នឹងមានផលប៉ះពាល់យ៉ាងពិតប្រាកដទៅដល់ភាពត្រឹមត្រូវ និងនិត្យានុកូលភាពនៃកិច្ចដំណើរការនីតិវិធីអ.វ.ត.ក។

---

[5] បញ្ហានេះតាមពិតទៅបានចាប់ផ្តើមតាំងពីឆ្នាំ២០០៧, *សូមមើល* UNDP, របាយការណ៍របស់ផ្នែកគ្រប់គ្រងធនធានមនុស្ស នៅ អ.វ.ត.ក, ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៧, របាយការណ៍លេខ RCM01; "ការចោទប្រកាន់អំពីអំពើពុករលួយនៅសាលក្តីខ្មែរក្រហមត្រូវតែស៊ើបអង្កេតឱ្យម៉ត់ចត់" Open Society Justice Initiative (ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧); ការដកខ្លួនរបស់ OSJI ដោយមិនមានការស៊ើបអង្កេតពីអំពើពុករលួយដែលត្រូវបានចោទប្រកាន់? ចៅក្រមកម្ពុជារបស់ អ.វ.ត.ក ចង់បានច្រកចេញដ៏ងាយមួយ៖ ចៅក្រមសាលាក្តីប្រល័យពូជសាសន៍ខ្មែរក្រហម ទាមទារដកខ្លួនពីការចោទប្រកាន់ពីអំពើពុករលួយ, កាសែត The Association Press (ចេញផ្សាយថ្ងៃសុក្រទី៩ ខែមីនា ឆ្នាំ២០០៧)។

[6] *សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សារណាតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីអំពីបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអំពីសំណើលើកទីដប់មួយសុំឱ្យមានកិច្ចស៊ើបអង្កេត*, ឯកសារ D158/5/3/10, ERN (ភាសាអង់គ្លេស) 00330867-00330879, កថាខណ្ឌ១៥ ។

## ផលប៉ះពាល់នៃរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យដល់ដំណើរការដ៏ត្រឹមត្រូវនៃសវនាការ

៥. ការបង្ហើបឲ្យដឹងនៃរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យគឺដើម្បីជួយសម្រួលឲ្យមានតម្លាភាពនៃតុលាការ។ បន្ថែមទៅនឹងអ្វីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង[7] តម្លាភាពនៅក្នុងតុលាការគឺជាតម្រូវការមួយនៅក្នុងចំណោមតម្រូវការដទៃទៀតដែលចាំបាច់ ដើម្បីធានាដល់កិច្ចដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ[8]។ ឧទាហរណ៍ដូចជាភាពត្រឹមត្រូវនៃសវនាការមួយ ត្រូវបានកាត់បន្ថយប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចស៊ើបអង្កេតបានវិភាគទៅលើព័ត៌មានដែលត្រូវលាក់កំបាំងដែលព័ត៌មាននេះអាចប៉ះពាល់ទៅដល់ផលប្រយោជន៍សាធារណៈ និងទប់ស្កាត់មិនឲ្យបង្ហើបប្រាប់ពីព័ត៌មានទាំងនេះ[9]។ ដូចបានបញ្ជាក់នៅក្នុងរឿងក្តី *Lubanga*[10]ក៏ដូចជារឿងក្តី *Jasper v. UK*[11]

---

[7] វិធាន២១ នៃវិធានផ្ទៃក្នុង។

[8] Wim Voermans, "តម្លាភាពតុលាការកំពុងបន្តរការទទួលខុសត្រូវសាធារណៈសម្រាប់តុលាការថ្មី" Utrecht Law Review, *Volume 3, លេខ១ (ខែមិថុនា) ២០០៧* អាចមើលបាននៅ http://www.utrechtlawreview.org/articles/000042/article.pdf

[9] សូមមើល *រឿងក្តី Condron តទល់ United Kingdom*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សេចក្តីសម្រេច, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០០, បណ្តឹងលេខ 35718/97, កថាខណ្ឌ ៦៥; *រឿងក្តី Allan តទល់ United Kingdom*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សេចក្តីសម្រេច, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០១, បណ្តឹងលេខ 36533/97, កថាខណ្ឌ៣៨ និងកថាខណ្ឌបន្តបន្ទាប់; *រឿងក្តី Dowsett តទល់ United Kingdom*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សេចក្តីសម្រេច, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៣, បណ្តឹងលេខ39482/98, កថាខណ្ឌ៤៤ និងកថាខណ្ឌបន្តបន្ទាប់; *សូមមើលផងដែរ រឿងក្តី F តទល់ Findland*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សេចក្តីសម្រេច, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧, បណ្តឹងលេខ 40412/98, កថាខណ្ឌ៧៨។

[10] *ស្ថានភាពក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យCongo, ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់ Thomas Lubanga Dyilo*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះI មានចំណងជើងថា "សេចក្តីសម្រេចលើផលវិបាកនៃការមិនបង្ហាញវត្ថុតាងដោះបន្ទុកដែលចែងក្នុងមាត្រា ៥៤(៣)(ង) ការព្រមព្រៀង និងពាក្យសុំតម្កល់ការកាត់សេចក្តីរបស់ជនជាប់ចោទ ជាមួយនឹងបញ្ហាជាក់លាក់ផ្សេងទៀតដែលត្រូវបានលើកឡើងនៅឯកិច្ចប្រជុំរៀបចំតុលាការ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨, ("Lubanga"), ICC-01/04-01/06 OA 13, 21-10-08, យោបល់ដាច់ដោយឡែករបស់ចៅក្រម Georghios M. Pikis, កថាខណ្ឌ៤៤។

[11] *រឿងក្តី Jasper តទល់ United Kingdom*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សេចក្តីសម្រេចនៅថ្ងៃទី១៦ ខែកុម្ភៈឆ្នាំ២០០០, បណ្តឹងលេខ 27052/95

ការត្រួតពិនិត្យតាមផ្លូវតុលាការមួយ តម្រូវឲ្យមានដើម្បីសម្រេចថា តើឯកសារណាមួយត្រូវបង្ហើបប្រាប់ឲ្យដឹង និងឯកសារណាដែលត្រូវរក្សាជាការសម្ងាត់។[12]

៦. ក្នុងករណីនេះ ទោះបីជាមានរបាយការណ៍ស៊ើបអង្កេតរបស់ការិយាល័យត្រួតពិនិត្យត្រូវបានផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែខ្លឹមសារនៃរបាយការណ៍នេះ ត្រូវរក្សាជាការសម្ងាត់ និងមិនត្រូវបានបង្ហើបឲ្យដឹងដល់សាធារណជន ឬភាគីនៅក្នុងកិច្ចដំណើការនីតិវិធី។[13] ដូច្នេះអង្គជំនុំជម្រះសាលាដំបូងដែលបំពេញនាទីជាស្ថាប័នត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងអ.វ.ត.ក ត្រូវសម្រេចថា តើរបាយការណ៍នេះត្រូវតែបង្ហើបឲ្យដឹង ប្រសិនបើរបាយការណ៍នេះមានពាក់ព័ន្ធដោយផ្ទាល់ទៅដល់សវនាការ និងអ.វ.ត.ក ទាំងមូល បញ្ហានេះគឺយោងទៅលើអង្គហេតុដែលថា ឯកសារនេះពាក់ព័ន្ធទៅនឹងអំពើពុករលួយដែលបានលើកឡើងដោយសាធារណជន។ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីទាំងនេះសមស្របទៅនឹងបទដ្ឋាននៃច្បាប់អន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងត្រូវតែធានាថាព័ត៌មានដែលបំរើដល់ផលប្រយោជន៍សាធារណជន គឺត្រូវបង្ហើបប្រាប់ឲ្យដឹង[14]។ ចំនុចនេះគឺពាក់ព័ន្ធទៅនឹងគោលការណ៍នៃសវនាការជាសាធារណៈ[15] ដើម្បីផ្តល់ឲ្យសាធារណជននូវសិទ្ធិក្នុងការដឹងថាតើយុត្តិធម៌ត្រូវបានផ្តល់ឲ្យពួកគាត់យ៉ាងដូចម្តេច។[16]

៧. នៅក្នុងបរិបទនេះ សាធារណជនមានសិទ្ធិក្នុងការដឹងនូវរាល់បញ្ហា ឬការប្រព្រឹត្តមិនត្រឹមត្រូវដែលធ្វើឲ្យខូចដល់កិច្ចដំណើរការនីតិវិធីរបស់អ.វ.ត.ក ពីព្រោះគោលដៅរបស់អ.វ.ត.ក គឺដើម្បីបំរើប្រយោជន៍សាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជា។ ទោះបីជាមានហានិភ័យដែលថាការបង្ហើបប្រាប់ឲ្យដឹងព័ត៌មាននេះដល់សាធារណជន នឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលមួយចំនួន

---

[12] *Jasper, ដូចដើងទំព័រខាងលើ; Lubanga, ដូចយោងខាងលើ។*

[13] *សំណើ, កថាខណ្ឌ៣*។

[14] *ដូចយោងខាងលើ* កំណត់សម្គាល់លេខ៨។

[15] គណកម្មាធិការសិទ្ធិមនុស្ស, អត្ថាធិប្បាយលេខ១៣, កថាខណ្ឌ៦, មាត្រា១០ នៃសេចក្តីប្រកាសជាសាកល, មាត្រា១៤(១) នៃ ICCPR, មាត្រា៦(១) នៃកតិការសញ្ញាអឺរុប, មាត្រា២០(៤) នៃលក្ខន្តិកៈ Yugoslavia, មាត្រា១៩(៤) នៃលក្ខន្តិកៈរ៉្វាន់ដា, មាត្រា៦៤(៧) និង ៦៧(១) នៃលក្ខន្តិកៈ ICC, មាត្រា១១ នៃសេចក្តីប្រកាសជាសកល, គោលការណ៍៣៦(១) នៃគោលការណ៍រួម, មាត្រា៨(៥) នៃកតិការសញ្ញាអាមេរិក និងមាត្រា XXVI នៃសេចក្តីប្រកាសអាមេរិក។

[16] អង្គការលើកលែងទោសអន្តរជាតិ, *Fair Trial Manual,* អាចរកមើលបាន

ដែលមានឈ្មោះនៅក្នុងរបាយការណ៍នោះក៏ដោយ ក៏យ៉ាងហោចណាស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធី ត្រូវតែបានគេផ្ដល់ឱ្យនូវសិទ្ធិក្នុងការទទួលបានព័ត៌មាននៅក្នុងរបាយការណ៍នេះ ពីព្រោះបញ្ហានេះពាក់ព័ន្ធទៅនឹងភាពពឹងផ្អែករបស់ពួកគាត់ទៅលើ អ.វ.ត.ក ក្នុងការស្វែងរកយុត្តិធម៌។

៨. វាគឺជាបញ្ហាមួយដ៏សំខាន់ដែលត្រូវកត់សម្គាល់ថា ការចោទប្រកាន់អំពីអំពើពុករលួយដែលអាចកើតមាននៅក្នុងការិយាល័យរដ្ឋបាលនឹងមានផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន។ បញ្ហានេះពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ការិយាល័យរដ្ឋបាលក្នុងការគាំទ្រ ក្នុងការផ្ដល់សេវា និងការត្រួតពិនិត្យដោយផ្នែកដល់អង្គជំនុំជម្រះរួមជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅ-ក្រមស៊ើបអង្កេត ហើយការិយាល័យរដ្ឋបាលគឺជាអ្នកទទួលខុសត្រូវក្នុងការដាក់រៀបចំកិច្ចដំណើរការនីតិវិធី[17]។ ដូច្នេះរាល់កំហុសទាំងឡាយនៅក្នុងផ្នែកសេវារដ្ឋបាល នឹងធ្វើឱ្យអន្តរាយដល់អនាគតនៃកិច្ចដំណើរការនីតិវិធី ឧទាហរណ៍ដូចជា មន្ត្រីទទួលបន្ទុកកិច្ចការច្បាប់ សំណុំរឿង បច្ចេកវិទ្យាព័ត៌មាន បកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ និងបុគ្គលិកបំរើការបច្ចេកទេសដទៃទៀតដែលបំពេញភារកិច្ចយ៉ាងសំខាន់ក្នុងការជួយគាំទ្រដល់កិច្ចដំណើរការនីតិវិធី[18]។

៩. ដូច្នេះការបង្ហើបឱ្យដឹងនូវរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យដល់សាធារណជន ឬយ៉ាងហោចណាស់ការបង្ហើបឱ្យដឹងជាសម្ងាត់នូវរបាយការណ៍នេះដល់ភាគីទាំងអស់ នឹងជួយគាំទ្រដល់ភាពត្រឹមត្រូវនៃដំណើរការសវនាការនៃរឿងក្ដីបច្ចុប្បន្ននេះ។ តាមរយៈការដឹងនូវលទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យត្រួតពិនិត្យនេះ គឺអាចផ្ដល់លទ្ធភាពឱ្យអង្គជំនុំជម្រះ និងភាគីចាត់វិធានការចាំបាច់សំខាន់ៗដើម្បីធានាថា សវនាការមិនត្រូវបានប្រឡាក់ប្រឡូក ជាមួយនឹងការចោទប្រកាន់នឹងអំពើពុករលួយ។ ភាគីទាំងអស់នៃរឿងក្ដីគួរចូលរួមដើម្បីធានាថាការគ្រប់គ្រងចាត់ចែងក្នុងតុលាការ ត្រូវបានប្រព្រឹត្តទៅដោយល្អត្រឹមត្រូវ និងដើម្បីការពាររាល់កំហុសឆ្គងទាំងឡាយដែលបានបង្ហើបឱ្យដឹងដោយរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យ។ ដូច្នេះនេះគឺដើម្បីការពារ

---

[17] វិធាន៩ នៃវិធានផ្ទៃក្នុង

[18] *សូមមើល រឿងក្ដី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២១), *សំណើលើកទី១១ ស្នើសុំបើកកិច្ចស៊ើបសួររបស់ នួន ជា,* ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ឯកសារលេខ D/158, កថាខណ្ឌ១៩។

ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសម្រេចសេចក្តីក្នុងសវនាការ ដោយផ្អែកលើគោលការណ៍យុត្តិធម៌ អនាគតិ និងឯករាជ្យភាព ក្នុងកិច្ចដំណើរការនីតិវិធី។

១០. លើសពីនេះទៅទៀត សារៈសំខាន់នៃបញ្ហានេះក្នុងកិច្ចដំណើរការនីតិវិធីរបស់អ.វ.ត.ក នាពេលអនាគត ជាពិសេសពាក់ព័ន្ធទៅនឹងគោលការណ៍សវនាការប្រកបដោយភាពត្រឹមត្រូវ គឺជាកាលៈទេសៈពិសេសដោយឡែកមួយដែលមានចែងនៅក្នុងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត ៥៩/២៧២[19] ដែលអនុញ្ញាតឲ្យភាគីទាំងអស់ទទួលបាននូវរបាយការណ៍នេះ។ យុត្តិធម៌ មិនមែនត្រឹមតែត្រូវស្វែងរកឲ្យឃើញនោះទេ ប៉ុន្តែត្រូវបង្ហាញឲ្យសាធារណជនឃើញផងដែរ[20]។ យើងជឿជាក់ថា តាមរយៈការបង្ហើបឲ្យដឹងពីរបាយការណ៍នៃការិយាល័យត្រួតពិនិត្យនេះ អ.វ.ត.ក នឹងបោះជំហានទៅមុខមួយជំហានទៀតយ៉ាងសំខាន់ក្នុងការធានាអំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីរបស់ខ្លួន។

## III. សំណើសុំ

១១. ដូចមានបញ្ជាក់ជូននូវហេតុផលទាំងអស់ខាងលើ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ សូមស្នើសុំដល់អង្គជំនុំជម្រះដល់ការយល់ព្រមតាមសំណើសុំនេះទាំងមូល។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៩

| | |
|---|---|
| លោក យុង ផានិត | លោកស្រី Silke STUDZINSKY |
| (អវត្តមាន) | សហមេធាវី |

[19] ឯកសារអ.ស.ប លេខ A/Res/59/272, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៥, កថាខណ្ឌ២; សំណើ, កថាខណ្ឌ៥។

[20] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តី Delcourt តទល់ Belgium,* ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧០, 11 Ser. A 17, កថាខណ្ឌ៣១។